ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ០៥ អយក.[illegible]

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការរៀបចំឯកសណ្ឋានបុគ្គលិកអប់រំ ក្នុងវិស័យអប់រំ យុវជន និងកីឡា

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញ អនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងផែនការសកម្មភាព នៃគោលនយោបាយស្តីពីគ្រូបង្រៀន ។

**ប្រការ១.**- ត្រូវបានបង្កើតគណៈកម្មការរៀបចំឯកសណ្ឋានបុគ្គលិកអប់រំ ក្នុងវិស័យអប់រំ យុវជន និងកីឡា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.លោកជំទាវ **គីម សេដ្ឋានី** | រដ្ឋលេខាធិការ | ប្រធាន |
| ២.លោកជំទាវ **យុន រចនា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣.ឯកឧត្តម **ថោង ម៉ូរ៉ាន់** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤.ឯកឧត្តម **ខួន មាស** | អគ្គនាយក នៃអគ្គ. រដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |

| | | |
|---|---|---|
| ៥.លោកបណ្ឌិត **ឌី សមស៊ីដេត** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៦.លោក **ឡៅ សុផន** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៧.លោក **ស៊ិន សេងហុក** | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៨.លោក **អ៊ុង ម៉ៅហុក** | ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | សមាជិក |
| ៩.លោក **ចាន់ សុភា** | ប្រធាននាយកដ្ឋានបឋមសិក្សា | សមាជិក |
| ១០.លោក **នេព តិយ្យារិទ្ធ** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ | សមាជិក |
| ១១.លោក **ហាន ឌីវីន** | ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ១២.លោក **ម៉ៅ ម៉េងឡុង** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ | សមាជិក |
| ១៣.លោក **ជ័យ សិទ្ធិ** | ប្រធានអង្គភាពលទ្ធកម្ម | សមាជិក |
| ១៤.លោក **អ៊ុច សុផល** | ប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល | សមាជិក |

គណៈកម្មការនេះ មានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- រៀបចំគំរូឯកសណ្ឋានរបស់បុគ្គលិកអប់រំ ដោយពិនិត្យជាមួយបណ្តាលប្រទេសនានាក្នុងតំបន់អាស៊ានមួយចំនួន
- រៀបចំស្ទង់មតិពីចំណង់ចំណូលចិត្តរបស់បុគ្គលិកអប់រំ និងអ្នកគ្រប់គ្រង លើគំរូ នៃការរចនាឯកសណ្ឋានបុគ្គលិកអប់រំ
- រៀបចំសំណើសុំការសម្រេចពីឯកឧត្តមថ្នាក់ដឹកនាំក្រសួង នូវគំរូឯកសណ្ឋានបុគ្គលិកអប់រំ
- រៀបចំគម្រោងផែនការថវិកា ក្នុងការកាត់ឯកសណ្ឋានបុគ្គិលអប់រំ
- សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្នើសុំថវិកាក្នុងការកាត់ឯកសណ្ឋាន
- អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៣.**- លោកជំទាវ ឯកឧត្តម លោក ដូចមានរាយនាមខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកុម្ភៈ ឆ្នាំ២០១៦

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា
  "ដើម្បីជ្រាបជាពត៌មាន"
- សាមីជន "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ នា.រដ្ឋបាល

បណ្ឌិត ហង់ ជួន ណារ៉ុន